## សំអាងហេតុក្នុងសេចក្តីសម្រេច

**(Legal Reasoning)**

យល់ឃើញថា *ការដែលតុលាការអង្គហេតុបានប្រកាសទោសលើជនជាប់ចោទឈ្មោះ...រ៉ា ដាក់ពន្ធនាគារ៣ខែ ក្នុងអង្គហេតុខាងលើនិងធ្វើការកែប្រែទោសពន្ធនាគារ១០ខែ ជាទោសព្យួរក្នុងសាលក្រមព្រហ្មទណ្ឌលេខ៨០"ច" ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៤ ដោយសំអាងថាជនជាប់ចោទប្រព្រឹត្តបទល្មើសក្នុងរយៈពេលសាកល្បងនោះ ការសម្រេចអំពីការដកហូតការព្យួរទោសបែបនេះ មិនទាន់មានការសំអាងហេតុគ្រប់គ្រាន់នៅឡើយទេ ព្រោះថាតាមស្មារតីមាត្រា៣ (គោលការណ៍នីត្យានុកូលភាព) កឋាខណ្ឌទី២នៃក្រមព្រហ្មទណ្ឌចែងថា "មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន" រីឯមាត្រា៥នៃក្រមដដែលកំណត់ថា ការបកស្រាយច្បាប់ព្រហ្មទណ្ឌត្រូវមានភាពតឹងរ៉ឹង។ ករណីនេះ តុលាការអង្គហេតុមិនទាន់បានបង្ហាញអំពីសំអាងហេតុទាក់ទិននឹងបញ្ញត្តិព្រហ្មទណ្ឌណាមួយ អនុញ្ញាតឲ្យធ្វើការដកហូតទោសព្យួរក្នុងនីតិវិធីនៃការប្រកាសដកហូតទោសព្យួរនោះទេ។ ដូច្នេះភាពមិនគ្រប់គ្រាន់នៃសំអាងហេតុ ចាត់ទុកថាគ្មានសំអាងហេតុយោងតាមស្មារតីមាត្រា៤១៩ ចំណុចទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការអង្គហេតុគប្បីពិចារណាជាថ្មី កុំឲ្យប៉ះពាល់ដល់គោលការណ៍នីត្យានុកូលភាពនៃទោសនៃច្បាប់ព្រហ្មទណ្ឌ។* (សាលដីកាលេខ២៥៦, ១៨ ខែតុលា ឆ្នាំ២០១៣, ទំ.៧)។

**<u>កំណត់សំគាល់</u>៖ ក.** ការបកស្រាយច្បាប់មានច្រើនវិធីសាស្ត្រ។ ក្នុងករណីរឿងព្រហ្មទណ្ឌ ការបកស្រាយត្រូវតែមានលក្ខណៈតឹងរឹង (មាត្រា៥) ក្នុងន័យថា មិនត្រូវបង្កើតបទល្មើសថ្មី ដែលសភាមិនបានធ្វើច្បាប់ចែងនូវបទល្មើសនោះ។ នេះឲ្យស្របនឹងគោលការណ៍នីត្យានុកូល។ ការបកស្រាយពន្លាត បង្កើតបទល្មើសថ្មី នឹងប្រឆាំងនឹងគោលការណ៍បែងចែកអំណាច (ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មាត្រា៥១ថ្មី)។ **ខ.** ជនជាប់ចោទមានសិទ្ធិប្តឹងឧទ្ធរណ៍ (មាត្រា១៤នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ) ដើម្បីប្តឹងបានលុះត្រាគាត់ដឹងអំពីសំអាងហេតុនៃសេចក្តីសម្រេច។ ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងតម្រូវនូវសំអាងហេតុក្នុងមាត្រា៣៥៧។ *គ្មានសំអាងហេតុ* ជាមូលដ្ឋាននៃការទទួលយកបណ្តឹងសាទុក្ខ។ ទោះបីជាយ៉ាងនេះក្តី ក្នុងសាលដីកានេះ តុលាការកំពូលបានជួយស្រាយបំភ្លឺអ្វីទៅ *គ្មានសំអាងហេតុ៖ ដូច្នេះភាពមិនគ្រប់គ្រាន់នៃសំអាងហេតុ ចាត់ទុកថាគ្មានសំអាងហេតុយោងតាមស្មារតីមាត្រា៤១៩ ចំណុចទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ*។ មានសាលដីកា មួយចំនួនទៀតចែងស្រដៀងនេះ។

មាត្រា**៣៥៧ការសរ**សេរសាលក្រម៖ ផ្នែកសំអាងហេតុនិងផ្នែកសម្រេច៖

គ្រប់សាលក្រមត្រូវតែមានពីរផ្នែក៖

-ផ្នែកសំអាងហេតុពោលផ្នែកទទ្បីករណ៍នៃអង្គហេតុនិងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្តីសម្រេច។

- ផ្នែកសម្រេចពោលផ្នែកសេចក្តីសម្រេចរបស់តុលាការ ។

អង្គហេតុត្រូវតែច្បាស់លាស់និងគ្មានការសង្ស័យ។ តុលាការត្រូវពិនិត្យមើលបទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបានលើកនៅពេលសវនាការ ។

នៅក្នុងសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី។

ផ្នែកសេចក្តីសម្រេចត្រូវចុះនិទ្ទេស អំពីបទល្មើសដែលជនជាប់ចោទ បានប្រព្រឹត្តខុសអត្ថបទច្បាប់ដែលអនុវត្តទោសនិងទណ្ឌកម្មរដ្ឋប្បវេណី ។